រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ៣៩៩.អយក.ប្រក**

**ស្តីពីការពង្រីកអនុវិទ្យាល័យ ទ្រៀលទៅជា « វិទ្យាល័យទ្រៀល »**

**ក្នុងស្រុកបារាយណ៍ខេត្ត កំពង់ធំ**

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ។
- យោងលិខិតលិខិតសំណើរបស់នាយកអនុវិទ្យាល័យទ្រៀលលេខ ១១៤ អន.ទ.៩៥ ចុះថ្ងៃទី ១៩ ធ្នូ ១៩៩៥ ដោយមានយោបលឯកភាពពីមន្ទីរអប់រំយុវជន និង កីឡា និង អភិបាលខេត្តកំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យទ្រៀល ទៅជា «**វិទ្យាល័យ ទ្រៀល** » ចាប់ពីឆ្នាំសិក្សា ១៩៩៦-៩៧ តទៅ នៅក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

**ប្រការ ២** : វិទ្យាល័យនេះ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេង ។ មួយចំនួនទៀត តាមអង្គការលេខ នៃវិទ្យាល័យ ។

**ប្រការ ៣** : នាយក-នាយករង នៃវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក នាយករង នៃវិទ្យាល័យ ។

**ប្រការ ៣** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា -ប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តកំពង់ធំ និង នាយកវិទ្យាល័យ **ខ្មេរ្វិល** មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

**តុល ឡោះ**

* * *

**ប្រកាសលេខ ៤០០ អយក.ប្រក**

**ស្តីពីការប្តូរឈ្មោះ «អនុវិទ្យាល័យ កោះចូរ៉ាម »ទៅជា**

**អនុវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន កោះចូរ៉ាម**

**ស្ថិតនៅក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល**

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ។
- យោងលិខិតរបស់គណៈកម្មការទ្រទ្រង់អនុវិទ្យាល័យកោះចូរ៉ាមលេខ ០៤/៩៦ អនុវិ.កចរ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ១៩៩៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំយុវជន និង កីឡា អភិបាលខេត្តកណ្តាល ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា